(៤៧)

# ប្រកាសស្ដីពី

## ការប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅរមផ្ទាល់តាមក្រសួងស្ថាប័ននៅ រដ្ឋបាលកណ្ដាលក្នុងការត្រួតពិនិត្យសម្រេចចុះ ទិដ្ឋាការលើលិខិតធានាចំណាយនិងលើអាណត្តិ បើកប្រាក់

លេខ: ១៤១៥ សហវ.ហក

ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ...០២៩... សហវ.ហក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ... ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## ការប្រគល់សិទ្ធិជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅបង្គាប់តាមក្រសួងស្ថាប័ននៅ រដ្ឋបាលកណ្តាលក្នុងការពិនិត្យសំរេចចុះទិដ្ឋាការលើលិខិតធានាចំណាយនិងលើអាណត្តិបើកប្រាក់

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអំពីប្រពន្ធ័ហិរញ្ញវត្ថុ និងបទប្បញ្ញត្តិនានានៃវិសោធនកម្មច្បាប់នេះ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ-បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ

140

- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៥៦សហវ.ប្រក ចុះថ្ងៃទី ១៤ ខែ មិនា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃនាយកដ្ឋានហិរញ្ញកិច្ច
- ផ្អែកតាមសកម្មភាព ៦.១.១ ស្តីពីការពិនិត្យឡើងវិញលើបទបញ្ញត្តិប្រកាសដែលកំពុងអនុវត្តលើការផ្តល់សិទ្ធិធានាចំណាយ និងអាណត្តិទូទាត់ ក្នុងក្របខណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- តាមស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦

## សម្រេច

ប្រការ១ : ប្រគល់សិទ្ធិសម្រេចទទួលខុសត្រូវចុះទិដ្ឋាការលើលិខិតធានាចំណាយ និងលើអាណត្តិបើកប្រាក់ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល សំរាប់មុខចំណាយមួយចំនួនដូចខាងក្រោម ÷

- ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់មន្ត្រីរាជការ ដែលមានទិដ្ឋាការយល់ព្រមពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- ប្រាក់កម្រៃរបស់បុគ្គលិកជាប់កិច្ចសន្យាឬបុគ្គលិកអណ្តែត ដែលមានទិដ្ឋាការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- មន្ត្រីមានជំងឺ និងឧបត្ថម្ភមន្ត្រីសំរាលកូន
- មរណៈភាព
- ឧបត្ថម្ភម្តងគត់ជូននិវត្តជន
- ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ
- ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ
- អាហារូបករណ៍សំរាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស ។

ប្រការ២ : មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ន មានសិទ្ធិសម្រេចទទួលខុសត្រូវចុះទិដ្ឋាការចំពោះមុខចំណាយមួយចំនួនដូចមានចែងក្នុងប្រការ ១ ខាងលើ ទៅតាមចំនួនទឹកប្រាក់ដូចខាងក្រោម ÷

- *មិនមានកំណត់ចំនួនទឹកប្រាក់សំរាប់មុខចំណាយ ÷*

+ ប្រាក់បៀវត្ស និងប្រាក់បំណាច់របស់មន្ត្រីរាជការ ដែលមានទិដ្ឋាការយល់ព្រមពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

+ ប្រាក់កម្រៃរបស់បុគ្គលិកជាប់កិច្ចសន្យា ឬបុគ្គលិកអណ្ដែត ដែលមានទិដ្ឋាការយល់ព្រមពីរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។

- *ក្រោមចំនួនទឹកប្រាក់ ៥០ លានរៀល សំរាប់មុខចំណាយដែលមានលក្ខណៈច្បាស់លាស់ដូចខាងក្រោម ÷*

+ ឧបត្ថម្ភមន្ត្រីមានជំងឺ និងឧបត្ថម្ភមន្ត្រីសំរាលកូន

+ ឧបត្ថម្ភមរណភាព

+ ឧបត្ថម្ភម្តងគត់ជូននិវត្តជន

+ ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ

+ ឧបត្ថម្ភដល់កូនកំព្រារបស់មន្ត្រីរាជការ

+ អាហារូបករណ៍សំរាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេស។

ប្រការ៣ : ភារកិច្ចទទួលខុសត្រូវរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលនៅអមផ្ទាល់តាមក្រសួងស្ថាប័ននៅរដ្ឋបាលកណ្តាលមានដូចខាងក្រោម ÷

- ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ ត្រឹមត្រូវ សមស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ-បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល និងសារាចរណែនាំលេខ ០០៥ សហវ-ហ.សរណន ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ

- មិនអនុញ្ញាតឱ្យធ្វើការបំបែកគំរោងចំណាយ ទៅជាគំរោងចំណាយតូចៗ ដើម្បីគេចវេសទៅតាមកំរិតទឹកប្រាក់ដែលបានប្រគល់សិទ្ធិសំរេច ។

- ត្រួតពិនិត្យជាមុនអំពីភាពត្រឹមត្រូវនៃការស្នើសុំចំណាយ ជាពិសេសត្រួតពិនិត្យអំពីភាពត្រឹមត្រូវនៃការធានាចំណាយជាមួយនឹងឥណទានទំនេរ និងផ្ទៀងផ្ទាត់រវាងការបញ្ចេញអាណត្តិទូទាត់ជាមួយនឹងកិច្ចសន្យាលទ្ធកម្មសាធារណៈ ។

- ត្រួតពិនិត្យពីភាពត្រឹមត្រូវនៃលិខិតយុត្តិការ (សក្ខីប័ត្រ) ដែលទាក់ទងនឹងសំណុំរឿងស្នើសុំចំណាយមុននឹងធ្វើការទូទាត់ ។

- ផ្តល់ការណែនាំអំពីនីតិវិធីចំណាយចំពោះថ្នាក់នានារបស់អាណាប័ក ក្នុងគោលបំណងបង្ការទុកជាមុននូវភាពមិនប្រក្រតី ដើម្បីចៀសវាងចំណាយគ្មានតម្លាភាព ឬចំណាយលើសពីឥណទានអនុម័តដែលធ្វើឱ្យរដ្ឋជំពាក់បំណុលគេ ។

- ត្រូវធ្វើការសិក្សាស្វែងយល់អំពីគោលនយោបាយជាអាទិភាពរបស់ក្រសួងសាមី ដើម្បីបង្កើនលទ្ធភាពឱ្យអាណាប័កចំណាយតាមគណនីនានាថវិកាដែលបានអនុម័ត ។ ប៉ុន្តែក៏ត្រូវអនុវត្តយ៉ាងហ្មត់ចត់នូវវិន័យថវិកា និងតាមលិខិតបទដ្ឋានដែលមានចែងជាធរមាន ។
- ត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារចំណាយ និងអាណត្តិចំណាយឱ្យបានទៀងទាត់ និងត្រឹមត្រូវ ដោយធ្វើការផ្ទៀងផ្ទាត់តួលេខអោយស៊ីគ្នាជាប្រចាំជាមួយនឹងផ្នែកគណនេយ្យរដ្ឋបាលរបស់អាណាប័ក និងជាមួយនឹងផ្នែកចំណាយរបស់រតនាគារជាតិ ។
- ធ្វើរបាយការណ៍ប្រចាំសប្តាហ៍អំពីការអនុវត្តន៍សិទ្ធិសម្រេចទទួលខុសត្រូវរបស់ខ្លួន ទាំងការធានាចំណាយ ទាំងការបញ្ជាអាណត្តិជូននាយកដ្ឋានហិរញ្ញកិច្ចឱ្យបានទៀងទាត់ ដើម្បីធ្វើការបូកសរុប ។

ប្រការ៤ : មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមថ្នាក់តាមក្រសួងស្ថាប័ន ត្រូវមានស្មារតីសាមគ្គីភាព និងរក្សានូវសីលធម៌វិជ្ជាជីវៈឱ្យបានត្រឹមត្រូវ ។

ប្រការ៥ : រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៦ : អគ្គលេខាធិការ នាយកខុទ្ទកាល័យទេសរដ្ឋមន្ត្រី ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលនៅអមថ្នាក់តាមក្រសួងស្ថាប័ន ព្រមទាំងប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៧ តទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់ក្រសួងស្ថាប័នដែលមានមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៅអមថ្នាក់
  "ដើម្បីសហការអនុវត្ត"
- គ្រប់នាយកដ្ឋាន អង្គភាព ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុពាក់ព័ន្ធដូចប្រការ៦
  "ដើម្បីអនុវត្ត"
- ឯកសារ និងកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation-Religion-King

********

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OFECONO MY AND FINANCE
FAX/PHONE:(855)2327798
លេខ ០០២ សហវ.ច

********

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៩

# សេចក្តីណែនាំ

## ស្តីពីរបៀបត្រួតពិនិត្យហិរញ្ញវត្ថុ

I. តួនាទី និង ភារកិច្ចរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ៖

១. ត្រួតពិនិត្យ និង ចុះទិដ្ឋាការដំបូងលើសន្យាចំណាយ និងត្រួតពិនិត្យចុះទិដ្ឋាការលើអាណត្តិកិច្ច មុននឹងបញ្ជូនទៅធ្វើការទូទាត់នៅរតនាគារ (ចុះទិដ្ឋាការលើគ្រប់ដំណាក់កាលនៃបរិវត្តចំណាយ) ។

២. ផ្តល់ដំបូន្មានដល់ផ្នែកហិរញ្ញវត្ថុរបស់អាណាប័ក ដើម្បីជួយកែលំអ និងបង្ការទុកជាមុននូវភាពមិនប្រក្រតី និងមិនត្រឹមត្រូវក្នុងកិច្ចប្រតិបត្តិការថវិកា និង ដើម្បីចៀសវាងការចំណាយលើសពីថវិកាដែលបានអនុម័ត ។

៣. ចូលរួមក្នុងការរៀបចំគំរោងថវិកា និងការតាក់តែងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា ។

៤. កាន់កាប់បញ្ជីគណនេយ្យចំណាយចុះសន្យា (ចំណាយវលក្ខិត) និងបញ្ជីគណនេយ្យចំណាយអាណាប័ណ្ណ ។

II. វិធីសាស្ត្រត្រួតពិនិត្យ ៖

វិធីសាស្ត្រនៃការត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវធ្វើឡើងទៅតាមដំណាក់កាល នៃបរិវត្តចំណាយ ៖

១. នៅដំណាក់កាលចុះសន្យាចំណាយ ៖

នៅដំណាក់កាលនេះគឺជាការត្រួតពិនិត្យ ដើម្បីចុះទិដ្ឋាការដំបូងទៅលើ "សលាកបត្រកក់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ" ។ ការត្រួតពិនិត្យនេះ គឺពិនិត្យលើ ៥ចំណុច ដូចខាងក្រោម ៖

- បន្ទុកចំណាយ ៖ គឺជាការត្រួតពិនិត្យលេខកូដរបស់ក្រសួង លេខកូដរបស់ផ្នែកចំណុះក្រសួង និងលេខកូដទីកន្លែង និង ត្រួតពិនិត្យអំពីលេខជំពូក, ប្រការ,កថាខ័ណ្ឌ, និង វាក្យខ័ណ្ឌនៃចំណាត់ថ្នាក់ចំណាយថវិកា ។
- ស្ថានភាពឥណទាន ៖ គឺត្រួតពិនិត្យឥណទានអនុម័តដំបូង, ការបង្វែរ,សរុបឥណទានអនុញ្ញាត, ការសន្យាចំណាយពីមុន, ចំនួនទឹកប្រាក់ត្រូវសន្យា, ឥណទាននៅទំនេរសំរាប់សន្យា ។
- ប្រភេទនៃការសន្យា ៖ គឺជាការត្រួតពិនិត្យអំពីមុខសញ្ញាចំណាយជាក់ស្តែង ដើម្បីឆ្លុះបញ្ចាំងឲ្យឃើញថាមុខសញ្ញាចំណាយពិតជាស្ថិតក្នុងចំណាត់ថ្នាក់ចំណាយដែលបានកក់ត្រាក្នុងបន្ទុកចំណាយ និង ឥណទានទំនេរសំរាប់សន្យានោះហើយឬទេ ? ជាពិសេសត្រូវឆ្លុះបញ្ចាំងឲ្យបានថា ថាមុខសញ្ញាចំណាយដែលបានគ្រោងក្នុងឥណទានអនុម័តរួចហើយ ។

- ផ្នែកទទួលបន្ទុកចំណាយ៖ គឺជាការត្រួតពិនិត្យដើម្បីឆ្លុះបញ្ចាំងឲ្យឃើញថា តើការចំណាយសមស្រប ទេ មិនគិតពីការងាររបស់ផ្នែកនានាចំណុះអង្គភាពដែលបានស្នើសុំ ឬទេ ?

- យុត្តិកម្មចំណាយ ឬសុពលភាព ៖ គឺជាការត្រួតពិនិត្យលើចំនួនលិខិតយុត្តិការដែលត្រូវបំពេញ និងភាពត្រឹមត្រូវនៃលិខិតយុត្តិការទាំងនោះ ។

៦. ដំណាក់កាលចុះទិដ្ឋាការអាណត្តិកិច្ច ៖

នៅដំណាក់កាលនេះ ការត្រួតពិនិត្យជាគោលសំខាន់គឺ ៖

- ផ្ទៀងផ្ទាត់ការចំណាយជាក់ស្តែងដែលបានធ្វើពិត ត្រឹមត្រូវពិតប្រាកដនៅការសម្រេចចំណាយឬទេ ? ដូច្នេះមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវត្រួតពិនិត្យឡើងវិញនូវអ្វីដែលខ្លួនបានត្រួតពិនិត្យ និងចុះទិដ្ឋាការសម្រេចចំណាយលើសាលាកបត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចុះនៅក្នុងអាណត្តិបើកប្រាក់ ។

- ពិនិត្យមើលតើការចំណាយបានអនុវត្តតាមបែបបទ នីតិវិធីជាធរមានដែរឬទេ ?

- ពិនិត្យមើលតើការចំណាយនេះបានបំពេញសំណុំលិខិតយុត្តិការគ្រប់គ្រាន់ និងត្រឹមត្រូវហើយឬនៅ ?

ខាងលើនេះ គឺជាការដកស្រង់ដោយសង្ខេបអំពីរបៀបត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីជាចំណេះដឹងដំបូងដល់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រីឯខ្លឹមសារលំអិត គឺមានចែងនៅក្នុងអនុក្រឹត្យលេខ ៨១អនក្រ.បក ចុះថ្ងៃទី១៦/១៧/១៩៩៤ របស់រាជរដ្ឋាភិបាល និងសារាចរណែនាំលេខ ០៥ សហវ.ហ សរណន ចុះថ្ងៃទី ២៧/០២/១៩៩៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលចាំបាច់ធ្វើការសិក្សាយល់ដឹងបន្ថែម ដើម្បីអនុវត្តការងារត្រួតពិនិត្យហិរញ្ញវត្ថុសំរេចបានលទ្ធផលល្អប្រសើរ ។/.

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល៖</u>

- មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុគ្រប់ខេត្ត ក្រុង
- ឯកសារ